# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៤៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និង ស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានកំណត់ផ្ទៃ បឹងជើងឯក និងប្រឡាយ ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និង ស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ មានផ្ទៃសរុបចំនួន ៥២០ ហិកតា (តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ Geocraphical Position System, GPS DATUM : INDIAN-THAILAND 1960 ) រួមមាន ៧៧ ចំណុច ដូចខាងក្រោម :

| ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ | ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|---|
| 1 | A1 | 489 333 | 1 273 464 | 40 | A40 | 490 766 | 1 271 173 |
| 2 | A2 | 489 296 | 1 273 388 | 41 | A41 | 490 830 | 1 271 059 |
| 3 | A3 | 489 509 | 1 273 330 | 42 | A42 | 490 865 | 1 270 467 |
| 4 | A4 | 489 469 | 1 273 025 | 43 | A43 | 490 883 | 1 270 392 |
| 5 | A5 | 489 357 | 1 273 047 | 44 | A44 | 491 487 | 1 270 391 |
| 6 | A6 | 489 346 | 1 273 098 | 45 | A45 | 491 483 | 1 270 632 |
| 7 | A7 | 489 294 | 1 273 112 | 46 | A46 | 491 433 | 1 270 710 |
| 8 | A8 | 489 251 | 1 273 244 | 47 | A47 | 491 383 | 1 270 937 |
| 9 | A9 | 489 063 | 1 273 258 | 48 | A48 | 491 763 | 1 271 641 |
| 10 | A10 | 489 001 | 1 273 205 | 49 | A49 | 491 896 | 1 272 343 |
| 11 | A11 | 488 885 | 1 272 683 | 50 | A50 | 491 865 | 1 272 375 |
| 12 | A12 | 488 997 | 1 272 665 | 51 | A51 | 492 085 | 1 273 048 |
| 13 | A13 | 489 191 | 1 272 397 | 52 | A52 | 492 177 | 1 273 131 |
| 14 | A14 | 489 365 | 1 272 300 | 53 | A53 | 492 315 | 1 273 833 |
| 15 | A15 | 489 527 | 1 272 564 | 54 | A54 | 492 311 | 1 274 030 |
| 16 | A16 | 489 740 | 1 272 707 | 55 | A55 | 492 284 | 1 274 106 |
| 17 | A17 | 490 041 | 1 272 799 | 56 | A56 | 492 212 | 1 274 075 |
| 18 | A18 | 490 204 | 1 272 816 | 57 | A57 | 492 170 | 1 273 927 |
| 19 | A19 | 490 238 | 1 272 669 | 58 | A58 | 491 967 | 1 273 826 |
| 20 | A20 | 490 130 | 1 272 642 | 59 | A59 | 491 874 | 1 273 593 |
| 21 | A21 | 490 117 | 1 272 445 | 60 | A60 | 491 872 | 1 273 101 |
| 22 | A22 | 490 145 | 1 272 362 | 61 | A61 | 491 957 | 1 273 045 |
| 23 | A23 | 490 205 | 1 272 192 | 62 | A62 | 491 977 | 1 272 990 |
| 24 | A24 | 490 088 | 1 272 130 | 63 | A63 | 491 784 | 1 272 429 |
| 25 | A25 | 490 089 | 1 271 868 | 64 | A64 | 491 769 | 1 272 416 |
| 26 | A26 | 490 011 | 1 271 868 | 65 | A65 | 491 747 | 1 272 419 |
| 27 | A27 | 489 991 | 1 271 975 | 66 | A66 | 490 705 | 1 273 042 |
| 28 | A28 | 489 881 | 1 272 077 | 67 | A67 | 489 793 | 1 273 269 |
| 29 | A29 | 489 760 | 1 272 088 | 68 | A68 | 489 758 | 1 273 311 |
| 30 | A30 | 489 624 | 1 271 703 | 69 | D1 | 488 504 | 1 269 053 |

| ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ | ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|---|
| 31 | A31 | 489.631 | 1 271 586 | 70 | D2 | 490 308 | 1 269 085 |
| 32 | A32 | 489 672 | 1 271 502 | 71 | D3 | 491 281 | 1 270 152 |
| 33 | A33 | 489 680 | 1 271 366 | 72 | D4 | 492 047 | 1 269 701 |
| 34 | A34 | 489 832 | 1 271 140 | 73 | D5 | 492 509 | 1 268 923 |
| 35 | A35 | 489 983 | 1 271 068 | 74 | D6 | 493 441 | 1 268 654 |
| 36 | A36 | 490 155 | 1 271 121 | 75 | D7 | 493 374 | 1 268 337 |
| 37 | A37 | 490 384 | 1 271 169 | 76 | D8 | 493 705 | 1 268 309 |
| 38 | A38 | 490 536 | 1 271 300 | 77 | D9 | 493 863 | 1 268 337 |
| 39 | A39 | 490 627 | 1 271 317 | | | | |

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងផ្ទៃបឹងជើងឯក និងប្រឡាយ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៨*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធៈ ផែនទីបង្ហាញទីតាំងបឹងជើងឯក

